មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៨

ព្រះហស្តលេខា

នរោត្តម សីហនុ

★ ★ ★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៧៨ អនក្រ.បក

### ស្តីពីការផ្ទេរឥណទាន

★ ★ ★

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៧ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៨ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកឥណទានក្នុងជំពូក តាមប្រការ កថាខណ្ឌ អនុកថាខណ្ឌ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

- បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការចំណាត់ថ្នាក់ចំណូល និង ចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .**_ ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ១០០ លានរៀល ( មួយរយលានរៀល ) ពីជំពូក៥០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនបានបែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ផ្គត់ផ្គង់តូចៗ ) របស់ក្រសួងបរិស្ថាន សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

**មាត្រា ២ .**_ ឥណទានថវិការក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ សំរាប់ចំណាយដំណើរការរដ្ឋបាល ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★ ★ ★

## អនុក្រឹត្យលេខ ២៣៨ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

★ ★ ★

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា